# 2 សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ

# ការសាងសង់រោងចំការ

នៅតាមតំបន់សាលាក្រុងភាគច្រើន លោកអ្នកត្រូវការដាក់ពាក្យសុំការអភិវឌ្ឍន៍ ដើម្បីសាងសង់រោងចំការនៅក្នុងអាជីវកម្មរបស់លោកអ្នក។ សូមទាក់ទងជាមួយបុគ្គលិកផែនការនៅតាមសាលាក្រុងក្នុងតំបន់របស់លោកអ្នក ដើម្បីពិភាក្សាអំពីបទបញ្ញាណាខ្លះដែលគ្រប់គ្រងលើដីធ្លីរបស់លោកអ្នក មុននឹងចាប់ផ្តើមគំរោងណាមួយ។

ដើម្បីធ្វើការសំរេចលើការដាក់ពាក្យសុំរបស់លោកអ្នក សាលាក្រុងត្រូវការចង់ដឹងអំពីគំរោងអ្វីមួយដែលលោកអ្នកបំរុងធ្វើ និងរបៀបដែលលោកអ្នកធ្វើគំរោងនោះ។ លោកអ្នកត្រូវចាំផងដែរថាបុគ្គលិកសាលាក្រុងខ្លះមិនមែនជាអ្នកជំនាញផ្នែកកសិកម្មទេ ហេតុនេះ លោកអ្នកត្រូវពន្យល់ប្រាប់គេអំពីអ្វីៗដែលមិនមែនជាចំណេះដឹងធម្មតា។

បន្ទាប់ពីលោកអ្នកបានដាក់ពាក្យសុំហើយ ភ្នាក់ងារសាលាក្រុងនឹងអញ្ជើញទៅមើលដីធ្លីរបស់លោកអ្នក ហេតុនេះសូមបំពេញពាក្យសុំឲ្យបានសព្វគ្រប់ត្រឹមត្រូវតាមដែលអាចធ្វើទៅបាន។



NSW DPI, Virginia Brunton

**ពាក្យសុំរបស់លោកអ្នកត្រូវទទួលការអនុញ្ញាតយល់ព្រមជាមុនសិន មុននឹងលោកអ្នកចាប់ផ្តើមធ្វើកិច្ចការណាមួយ។ ប្រសិនបើលោកអ្នកមិនបានទទួលច្បាប់អនុញ្ញាតយល់ព្រមជាមុនទេនោះ វាអាចបណ្តាលឲ្យមានបញ្ហាយឺតយូរ ឬអាចទទួលការផាកពិន័យ។**



NSW DPI, Steven Honeywood

## សំណួរទូទៅដែលត្រូវគិត មុននឹងចាប់ផ្តើមការសាងសង់រោង:

- តើខ្ញុំនឹងសាងសង់រោងនោះនៅជិតព្រំប្រទល់ដីយ៉ាងណាដែរ? ត្រូវស្វែងរកឲ្យបានដឹងអំពីចម្ងាយជិតបំផុតពីព្រំប្រទល់ដីដែលលោកអ្នកត្រូវបានអនុញ្ញាតឲ្យសាងសង់។
- តើខ្ញុំត្រូវធ្វើដូចម្តេចអំពីទឹកភ្លៀងហូរចុះពីដំបូលរោងចំការ? លោកអ្នកអាចរក្សាទុកទឹកនៅក្នុងធុងទឹក ឬទំនប់ទឹក ឬប្រសិនបើទឹកនោះវាមិនក្រខ្វក់ លោកអ្នកអាចបង្ហូរចូលទៅក្នុងប្រព័ន្ធទឹកហូរ ឬប្រឡាយបង្ហូរទឹកសាធារណៈ។ មិនត្រូវបណ្តោយឲ្យទឹកភ្លៀងហូរចុះពីដំបូលធ្វើឲ្យច្រោះដីឡើយ។ ការច្រោះដីគឺជាការរំពើកកំរើកដីបណ្តាលមកពីទឹកហូរខ្លាំងពេក។
- តើខ្ញុំអាចរស់នៅក្នុងរោងចំការរបស់ខ្ញុំបានឬទេ? ពុំបានទេ លោកអ្នកមិនអាចរស់នៅក្នុងរោងនោះបានឡើយ។
- តើខ្ញុំអាចកាប់ដើមឈើបានឬទេដើម្បីសាងសង់រោង? គឺពឹងផ្អែកទៅលើជំពូកដើមឈើ ការកាប់នេះមិនអាចចេះតែធ្វើទៅបានទេ ហើយជួនកាលលោកអ្នកត្រូវដាក់ពាក្យសុំច្បាប់អនុញ្ញាតដោយឡែកផ្សេងទៀត។ សាលាក្រុងនីមួយៗមានគំរោងបរិដ្ឋាន។ លោកអ្នកនឹងត្រូវការពាក្យសុំច្បាប់អនុញ្ញាតដោយឡែក ប្រសិនបើដើមឈើនោះមិនបានកត់ចុះថាជាជំពូកដើមឈើដែលបានលើកលែងនៅក្នុងគំរោងបរិដ្ឋាន។ លោកអ្នកអាចទទួលយកពាក្យសុំកាប់ដើមឈើចេញពីដីធ្លីឯកជនពី ការិយាល័យបំរើអតិថិជននៅឯសាលាក្រុងរបស់លោកអ្នក ឬនៅតាមវិបសាយរបស់សាលាក្រុង។
- តើខ្ញុំអាចសាងសង់រោងនៅតាមតំបន់ដីលេចទឹកបានឬទេ? តំបន់ដីលេចទឹកគឺជាតំបន់ដែលស្ថិតនៅក្នុងសភាពគ្រោះថ្នាក់នៃការលេចទឹកពីស្ទឹង ឬព្រែក។ រោងដែលសង់នៅតាមតំបន់ដីលេចទឹកនឹងតម្រូវឲ្យមានការគិតពិចារណាពិសេស។

សាលាក្រុងនីមួយៗមានច្បាប់របស់ខ្លួនផ្សេងៗគ្នា ហេតុនេះសូមទូរស័ព្ទដើម្បីពិភាក្សាអំពីពាក្យសុំរបស់លោកអ្នកជាមួយបុគ្គលិកផែនការជាមុន មុននឹងចាប់ផ្តើមការសាងសង់រោងចំការ។

**ដើម្បីទទួលយកព័ត៌មានបន្ថែមទៀតអំពីការដាក់ពាក្យសុំ សូមអានសន្លឹកព័ត៌មានសំរាប់អ្នកដំណាំលក់តាមទីផ្សារពាក្យសុំការអភិវឌ្ឍន៍។**

**សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយៈមូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសេរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្តី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្តីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែច្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST